# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ២១ ក្រ៥ “ធ”
ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ៥៩៨៨
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ៤៤៩៤
ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ២៦៥០
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥៩៨៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ ដែលមាន**ជនជាប់ចោទ៖**

-ឈ្មោះ [redacted] **ឧត្តម** ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកហាងម៉ាស្សា ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេ[redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ឌឿង “រ” ម្តាយឈ្មោះ [redacted] ណារ “រ” ជានីតិជន ទោសពីមុនគ្មាន។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៨៩៩ “ច១” ដ.ឃ.ដ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ដីកាបង្គាប់ឱ្យដោះលែងលេខ ១៥៣៤ “ល” ដ.ឃ.ដ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញពេញ។

ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ១២៧៦ “ល” ដ.ព.ស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ជាប់ចោទពីបទ **សញ្ញារកម្មមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្ទះលេខ៣៣ ផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីអំឡុងដើមឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥ និងមាត្រា២៧ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីនិច ភេទស្រី អាយុ ១៧ឆ្នាំ អាសយដ្ឋាននៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] លីលី ភេទស្រី អាយុ ១៧ឆ្នាំ អាសយដ្ឋាននៅភូមិព្រៃកុដិ សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ[redacted] **ចាន់ផន** ភេទស្រី អាយុ ២៨ឆ្នាំ អាសយដ្ឋានផ្ទះលេខ៣២ ស្រុកអង្គស្នួល ខេត្តកណ្តាល។



Scanned with CamScanner

ជនរងគ្រោះឈ្មោះ [redacted] ស្រីតុង ភេទស្រី អាយុ ២១ឆ្នាំ អាសយដ្ឋានផ្ទះជួល ផ្លូវ២០០៤ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] សៀងហៃ ភេទស្រី អាយុ ២២ឆ្នាំ អាសយដ្ឋានផ្ទះជួល ផ្លូវ២០០៤ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] ធីតា ភេទស្រី អាយុ ២៦ឆ្នាំ អាសយដ្ឋានផ្ទះជួល សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

មេធាវី [redacted] អត្តលេខ [redacted] មេធាវី [redacted] និងមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

## អង្គហេតុនៃរឿងមានដូចតទៅ

នៅក្នុងអំឡុងឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ៣៥ឆ្នាំ បានជួលផ្ទះចំនួន ០២កន្លែង ដើម្បីបើកហាងម៉ាស្សា និងបង្កប់សេវាកម្មរួមភេទ ដោយទីតាំងទី១ យីហោឈ្មោះ កុលាបក្រហម១៦៨ ផ្ទះលេខ៣៣ ផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ តម្លៃ ៣០០ដុល្លារអាមេរិក ក្នុងមួយខែ មានចំនួន ០៣បន្ទប់ និងទីតាំងទី២ ផ្ទះលេខ២៨១ ផ្លូវបេតុងទី១០ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ តម្លៃ ៤០០ដុល្លារអាមេរិក ក្នុងមួយខែ មានចំនួន ០៣បន្ទប់។ ចំពោះតម្លៃម៉ាស្សាក្នុងទីតាំងខាងលើក្នុងមួយម៉ោងតម្លៃ ០២ម៉ឺនរៀល ហើយជនជាប់ចោទឈ្មោះ [redacted] ឧត្តម ដកចំនួន ០១ម៉ឺនរៀល ហើយប្រសិនបើរួមភេទជាមួយភ្ញៀវ គឺជនជាប់ចោទដកចំនួន ០២ម៉ឺនរៀល បន្ថែមទៀត។ ចំពោះទីតាំងទី២ រកចំណូលបានចន្លោះពី១៥ម៉ឺនរៀល ទៅ២៥ម៉ឺនរៀល ក្នុងមួយថ្ងៃ។ រហូតដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះបង្ក្រាបទីតាំងខាងលើ ដោយឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ឧត្តម អាយុ ៣៥ឆ្នាំ និងបានជួយសង្គ្រោះបានជនរងគ្រោះចំនួន ០៨នាក់ ក្នុងនោះមានអនីតិជនចំនួន ០២នាក់។

-បានឃើញ របាយការណ៍សំយោគលេខ៣០០/២២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៤៥០៩ អ.យ.ធ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ២១៤០ អ.យ.ធ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២៨៤២ "ល" ដ.ដ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-តាមអំណានលើចម្លើយជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ថា ចម្លើយដែលបានឆ្លើយនៅមុខមន្ត្រីនគរបាលយុត្តិធម៌ គឺខ្លួនសូមបដិសេធគ្រប់ចំណុច មានកន្លែងទទួលសេវារួមភេទ គឺមានតែសេវាម៉ាស្សាធម្មតា ចំពោះទំនាក់ទំនងរួមភេទ គឺអាស្រ័យទៅលើការសម្រេចចិត្តរបស់សាមីខ្លួន ខ្លួនពុំបានដឹងឮ ឬគម្រាមកំហែងបង្កាប់បញ្ជា និងទទួលផលពីសេវារួមភេទ នោះទេ។ ខ្លួនបានចាប់ផ្តើមបើកហាងម៉ាស្សានៅដើមឆ្នាំ២០២២ ដែលមានហាងម៉ាស្សាឈ្មោះ កុលាបក្រហម ១៦៨ ដែលមាននារីម៉ាស្សាចាប់ពី០២នាក់ ទៅ ០៤



Scanned with CamScanner

នាក់ ហើយតម្លៃក្នុងការ ម៉ាស្សា ០១ម៉ោង ២ម៉ឺនរៀល ខ្លួនដកយក១ម៉ឺនរៀល និង១ម៉ឺនរៀលទៀត គឺខ្លួនឱ្យទៅនារីម៉ាស្សា។ ក្នុងមួយថ្ងៃខ្លួនអាចរកចំណូលបានចន្លោះពី ៥ម៉ឺនរៀល ទៅ ១០ម៉ឺនរៀល ឬអាចអត់មានក៏មានដែរ។ ចំពោះទីតាំងទី២ នោះខ្លួនទើបបើកបាន០៧ថ្ងៃនោះទេ ពុំទាន់មានឃីហោនោះទេ។ ចំពោះនារីម៉ាស្សាដែលបានរួមភេទនៅក្នុងហាងម៉ាស្សារបស់ខ្លួន គឺខ្លួនពុំបានដឹងនោះទេ ហើយក៏មិនបានដកយកកម្រៃបន្ថែមពីនាទីទាំងនោះដែរ។ ខ្លួនស្នើសុំឱ្យតុលាការកុំឃុំខ្លួនរូបខ្លួន ដោយមូលហេតុខ្លួនមានជំងឺប្រចាំកាយដូចជាជំងឺអេសដ៍ ជំងឺមហារីកស្បែក និងជំងឺថ្លើមប្រភេទB។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ថា ក្នុងរយៈពេលដែលខ្លួនជាប់ឃុំខ្លួនមួយរយៈពេលកន្លងមកនេះ គឺខ្លួនបានដឹងកំហុស និងចេតនាកែប្រែខ្លួន ដើម្បីចូលក្នុងសង្គមវិញហើយ។

-តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីនិច បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា ខ្លួនស្គាល់ឈ្មោះ [redacted] ឧត្តម ដោយគាត់ជាថៅកែរបស់ខ្លួន។ ខ្លួនចូលធ្វើការនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២។ នៅពេលខ្លួនចូលធ្វើការជាមួយឈ្មោះ [redacted] ឧត្តម គឺចូលធ្វើការជាអ្នកម៉ាស្សា ដោយនៅពេលដែលខ្លួនម៉ាស្សាឱ្យភ្ញៀវ គឺខ្លួន និងភ្ញៀវនិយាយគ្នារួមភេទជាមួយគ្នា ដោយថៅកែរបស់ខ្លួនឈ្មោះ [redacted] ឧត្តម មិនបានដឹងនោះទេ ហើយពេលរួមភេទ គឺរួមភេទនៅក្នុងបន្ទប់ម៉ាស្សា ព្រោះបន្ទប់ម៉ាស្សានៅទីនោះធ្វើសម្រាប់ទទួលភ្ញៀវម៉ាស្សាមួយបន្ទប់ម្នាក់ៗ។ ខ្លួនចូលទៅធ្វើការនៅហាងម៉ាស្សារបស់ឈ្មោះ [redacted] ឧត្តម គឺដោយសារខ្លួនស្គាល់មិត្តភក្តិរបស់បងស្រី ដែលរាប់អានគ្នាធ្វើការនៅទីនោះ ទើបខ្លួនសុំឈ្មោះ [redacted] ឧត្តម ចូលធ្វើការ។ មុនពេលដែលខ្លួនចូលធ្វើការនៅហាងម៉ាស្សារបស់ឈ្មោះ [redacted] ឧត្តម គឺខ្លួនធ្វើការម៉ាស្សានៅហាងផ្សេង ប៉ុន្តែខ្លួនឈប់ដោយសារតែខ្លួនមិនត្រូវគ្នាជាមួយម្ចាស់ហាង។ នៅពេលខ្លួនធ្វើការនៅហាងម៉ាស្សាមុន ខ្លួនមិនធ្លាប់រួមភេទជាមួយភ្ញៀវទេ ទើបតែចូលហាងម៉ាស្សារបស់ឈ្មោះ [redacted] ឧត្តម ដែលខ្លួនរួមភេទជាមួយភ្ញៀវ ហើយការរួមភេទជាមួយភ្ញៀវនេះ គឺគ្មានអ្នកណាបង្ខិតបង្ខំ ឬគំរាមកំហែងខ្លួនទេ ដោយខ្លួនស្ម័គ្រចិត្តខ្លួនឯង ព្រោះខ្លួនចង់បានលុយ។ ចំពោះថ្លៃម៉ាស្សាភ្ញៀវម្នាក់តម្លៃ ៥ដុល្លារអាមេរិក ខ្លួនទទួលបាន ១០,០០០រៀល ហើយថៅកែទទួលបាន ១០,០០០រៀល។ ចំពោះការរួមភេទជាមួយភ្ញៀវ គឺខ្លួនទទួលបានម្នាក់ ២០ ដុល្លារអាមេរិក ទៅ ២៥ ដុល្លារអាមេរិក ដោយប្រាក់នេះ ខ្លួនជាអ្នកកំណត់យកពីភ្ញៀវខ្លួនឯង ហើយខ្លួនជាអ្នកទទួលលុយខ្លួនឯងផ្ទាល់ទាំងថ្លៃម៉ាស្សា និងថ្លៃរួមភេទ។ នៅពេលដែលខ្លួនរួមភេទជាមួយភ្ញៀវម្តង គឺខ្លួនឱ្យទៅថៅកែឈ្មោះ [redacted] ឧត្តម ចំនួន ១៥,០០០រៀល។ ចំពោះថៅកែឈ្មោះ [redacted] ឧត្តម នៅពេលដែលខ្លួនរួមភេទជាមួយភ្ញៀវរួច ទើបដឹងថាខ្លួនរួមភេទជាមួយភ្ញៀវ។ ចំពោះការម៉ាស្សា ហើយរួមភេទជាមួយភ្ញៀវ គឺខ្លួនមិនដឹងថា អ្នកធ្វើការនៅក្នុងកន្លែងម៉ាស្សានោះ គេធ្វើដូចខ្លួនដែរឬអត់នោះទេ ដោយខ្លួនមិនដឹងថា មានអ្នកម៉ាស្សាណាខ្លះរួមភេទជាមួយភ្ញៀវនោះទេ។ បច្ចុប្បន្នខ្លួនស្នាក់នៅមណ្ឌលអង្គការមេត្រីអន្តរជាតិ រៀនផ្នែកសាឡន និងចំណេះដឹងទូទៅ ហើយពេលចេញពីមណ្ឌលវិញ ខ្លួននឹងកែខ្លួនឈប់ទៅប្រព្រឹត្តបែបនេះទៀតហើយ។

-តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] លើលី បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា ខ្លួនស្គាល់ឈ្មោះ [redacted] ឧត្តម ដោយគាត់ជាថៅកែរបស់ខ្លួន។ ខ្លួនចូលធ្វើការនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២។ នៅពេលខ្លួនចូលធ្វើការជាមួយឈ្មោះ [redacted] ឧត្តម គឺចូលធ្វើការជាអ្នកម៉ាស្សា ដោយនៅពេលដែលខ្លួន ម៉ាស្សាឱ្យភ្ញៀវ គឺខ្លួន និងភ្ញៀវនិយាយគ្នារួមភេទជាមួយគ្នា ដោយថៅកែរបស់ខ្លួនឈ្មោះ [redacted] ឧត្តម មិនបានដឹងនោះទេ ព្រោះពេលខ្លះគាត់មិននៅ ហើយពេលរួមភេទ គឺរួមភេទនៅក្នុងបន្ទប់ម៉ាស្សា ព្រោះបន្ទប់ម៉ាស្សានៅទីនោះធ្វើសម្រាប់ទទួលភ្ញៀវម៉ាស្សាមួយបន្ទប់ម្នាក់ៗ។ ខ្លួនចូលទៅធ្វើការនៅហាងម៉ាស្សារបស់ឈ្មោះ [redacted] ឧត្តម គឺដោយសារខ្លួនស្គាល់មិត្តភក្តិធ្វើការនៅទីនោះ ទើបខ្លួនសុំឈ្មោះ [redacted] ឧត្តម ចូលធ្វើការ។ មុនពេលដែលខ្លួនចូលធ្វើការនៅហាងម៉ាស្សារបស់ឈ្មោះ [redacted] ឧត្តម គឺ

ខ្លួនធ្វើការម៉ាស្សានៅហាងផ្សេង ហើយក៏ធ្លាប់រួមភេទជាមួយភ្ញៀវដែរ។ ខ្លួនឈប់ធ្វើការនៅហាងម៉ាស្សាមុន ដោយសារតែខ្លួនឈ្លោះគ្នាជាមួយអ្នកធ្វើការនៅទីនោះ។ នៅពេលខ្លួនធ្វើការនៅហាងម៉ាស្សារបស់ឈ្មោះ [redacted] ឧត្តម ខ្លួនរួមភេទជាមួយភ្ញៀវនោះ គឺគ្មានអ្នកណាបង្ខិតបង្ខំ ឬគំរាមកំហែងខ្លួនទេ ដោយខ្លួនស្ម័គ្រចិត្តដោយខ្លួនឯង ព្រោះខ្លួនចង់បានលុយ។ ចំពោះថ្លៃម៉ាស្សាភ្ញៀវម្នាក់តម្លៃ ៥ដុល្លារអាមេរិក ខ្លួនទទួលបាន ១០,០០០រៀល ហើយថៅកែទទួលបាន ១០,០០០រៀល។ ចំពោះការរួមភេទជាមួយភ្ញៀវ គឺខ្លួនទទួលបានម្នាក់ ២០ ដុល្លារអាមេរិក ទៅ ២៥ដុល្លារអាមេរិក ដោយប្រាក់នេះ ខ្លួនជាអ្នកកំណត់យកពីភ្ញៀវខ្លួនឯង ហើយខ្លួនជាអ្នកទទួលលុយខ្លួនឯងផ្ទាល់ទាំងថ្លៃម៉ាស្សា និងថ្លៃរួមភេទ។ នៅពេលដែលខ្លួនរួមភេទជាមួយភ្ញៀវម្តង គឺខ្លួនឱ្យទៅថៅកែឈ្មោះ [redacted] ឧត្តម ចំនួន ១៥,០០០រៀល។ ចំពោះថៅកែឈ្មោះ [redacted] ឧត្តម នៅពេលដែលខ្លួនរួមភេទជាមួយភ្ញៀវរួច ទើបដឹងថាខ្លួនរួមភេទជាមួយភ្ញៀវ។ ពេលខ្លួនប្រាប់ថា រួមភេទជាមួយភ្ញៀវ គឺគាត់មិនដែលនិយាយអ្វីទេ ហើយក៏មិនដែលហាមខ្លួនដែរ ប្រសិនបើខ្លួនមិនប្រាប់គាត់ថា ខ្លួនរួមភេទជាមួយភ្ញៀវ គាត់ក៏មិនដឹងដែរ ព្រោះគាត់មិនសូវនៅហាងទេ។ ចំពោះការម៉ាស្សា ហើយរួមភេទជាមួយភ្ញៀវនៅក្នុងហាងរបស់ឈ្មោះ [redacted] ឧត្តម ក្រៅពីខ្លួន ក៏មានអ្នកផ្សេងទៀតធ្វើដែរ ព្រោះខ្លួនធ្លាប់លឺគេនិយាយគ្នា។ បច្ចុប្បន្នខ្លួនស្នាក់នៅមណ្ឌលអង្គការមេត្រីអន្តរជាតិ រៀនផ្នែកសាឡន និងចំណេះដឹងទូទៅ ហើយពេលចេញពីមណ្ឌលវិញ ខ្លួននឹងកែខ្លួនឈប់ទៅប្រព្រឹត្តបែបនេះទៀតហើយ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ

-មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ បានធ្វើសេចក្តីសន្និដ្ឋានថា ថ្វីត្បិតតែជនជាប់ចោទអវត្តមាន ប៉ុន្តែតាមអំណានចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលស៊ើបសួរ ឃើញថា គាត់បានឆ្លើយបដិសេធ ប៉ុន្តែគាត់បានឆ្លើយសារភាពនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដោយបានបញ្ជាក់យ៉ាងច្បាស់ថា បើជនរងគ្រោះរួមភេទជាមួយភ្ញៀវ គឺខ្លួនដឹងតែដកយក ២០,០០០រៀល ដូច្នេះចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនៅចំពោះមុខសមត្ថកិច្ចនេះ ឃើញថាមានភាពស៊ីសង្វាក់ទៅនឹងចម្លើយជនរងគ្រោះ ដែលបានបញ្ជាក់ថាបន្ទាប់ពីរួមភេទហើយ គឺខ្លួនបានដកប្រាក់ឱ្យថៅកែឈ្មោះ [redacted] ឧត្តម ចំនួន ១៥,០០០រៀល។ ចម្លើយទាំងនេះមានភាពស៊ីសង្វាក់ដែលអាចបន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ឧត្តម ពីបទ សញ្ចារកម្មមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់ប្រាកដមែន។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ សំណូមពរសុំឱ្យក្រុមប្រឹក្សាសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដោយឡែកចំពោះសំណង កូនក្តីខ្លួនមិនទាមទារនោះទេ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សាដេញដោលនេះ ឃើញថាជនជាប់ចោទឈ្មោះ [redacted] ឧត្តម ពិតជាបានប្រព្រឹត្តអំពើសញ្ចារកម្មមានស្ថានទម្ងន់ទោស ប្រាកដមែន។ ផ្អែកតាមអង្គហេតុ និងភស្តុតាងដែលមានក្នុងសំណុំរឿង តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោតបានធ្វើសេចក្តីសន្និដ្ឋានថា ផ្អែកតាមឯកសារក្នុងសំណុំរឿងឃើញថា តំណាងអយ្យការបានចោទប្រកាន់កូនក្តីខ្លួនពីបទ សញ្ចារកម្មមានស្ថានទម្ងន់ទោស ហើយកូនក្តីខ្លួនបានសហការ និងបានឆ្លើយសារភាពគ្រប់ដំណាក់កាលទាំងអស់ ដូច្នេះសុំក្រុមប្រឹក្សាពិចារណាស្ថានសម្រាលតាមមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ ដល់កូនក្តីខ្លួន ព្រោះកូនក្តីខ្លួនបានឆ្លើយសារភាពនៅគ្រប់នីតិវិធី។ ជាចុងបញ្ចប់ ក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំស្ថានសម្រាលដល់កូនក្តី ដោយហេតុថាកូនក្តខ្លួនមិនដែលបានប្រព្រឹត្តបទល្មើសនាពេលកន្លងមកនោះទេ ហើយកូនក្តីខ្លួនក៏មានប្រចាំកាយដូចជាជំងឺអេដស៍ ជំងឺថ្លើមB និងមហារីកស្បែក ដែលមានសំបុត្រពេទ្យជាភស្តុតាងផងដែរ ហើយលើសពីនេះទៀត ដើម្បីឱ្យកូនក្តីខ្លួនកែប្រែកំហុស និងកសាងខ្លួនជាមនុស្សល្អក្នុងសង្គមឡើងវិញផងដែរ។



Scanned with CamScanner

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណាងចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២៨៤២ “ល” ជ.ង ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ **សញ្ញារកម្មមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្ទះលេខ៣៣ ផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីអំឡុងដើមឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥ និងមាត្រា២៧ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរលើកទី២ ថា ខ្លួនបានដឹងកំហុសហើយ ដែលចម្លើយនេះស្របនឹងចម្លើយដែលជនជាប់ចោទបានឆ្លើយសារនៅចំពោះមុខសមត្ថកិច្ចថា ខ្លួនពិតជាដកលុយនៅពីស្រីៗ ដែលជាបុគ្គលិករបស់ខ្លួននៅពេលដែលបានរួមភេទជាមួយភ្ញៀវប្រាកដមែន។

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទមានស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះ និងភស្តុតាងនានា ក៏ដូចជារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើសញ្ញារកម្មមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់ប្រាកដមែន។

៤-ជនជាប់ចោទជានីតិជន មានស្មារតីគ្រប់គ្រាន់ និងនីតិសម្បទាបរិបូរណ៍ ហើយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានសតិវិបល្លាសស្មារតី ក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដូច្នេះជនជាប់ចោទជាសមត្ថជនអាចពិចារណា និងយល់ដឹងអំពីព្យសនកម្មដែលកើតចេញពីអំពើរបស់ខ្លួន ហើយលក្ខខណ្ឌគតិយុត្តិតម្រូវឱ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងត្រូវបានច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។

៦-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ ដែលបានសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទមានមូលដ្ឋានសមស្រប គប្បីតុលាការពិចារណា។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ដែលបានប្តឹងសុំតម្កល់ការចោទប្រកាន់នោះ មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ គប្បីតុលាការពិចារណា។

៨-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលបានសុំឱ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួននោះ ពុំមានមូលដ្ឋានគ្រប់គ្រាន់អាចឱ្យតុលាការពិចារណាបានឡើយ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ ពីបទ **សញ្ញារកម្មមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្ទះលេខ៣៣ ផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីអំឡុងដើមឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យ ផ្តន្ទាទោសតាមមាត្រា២៥ និងមាត្រា២៧ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។



Scanned with CamScanner

១០-តាមកំណត់ហេតុទទួលវត្ថុចាប់យក(១)លេខ២៣០៧ រ.វ.ត/២២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលវត្ថុចាប់យករួមមាន៖

ក-រថយន្តចំនួន ០១(មួយ)គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2BK-3543 វត្ថុតាងនេះ ត្រូវបានចៅក្រមស៊ើបសួរសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញតាមដីកាសម្រេចលេខ១០៣ “ល” ព្រ.ទ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ រួចហើយ។ ដូចនេះ តុលាការមិនពិចារណាទៀតឡើយ។

ខ-រថយន្តចំនួន ០១(មួយ)គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ ពាក់ផ្លាកលេខ ភ្នំពេញ 2BD-1154 វត្ថុតាងនេះ ត្រូវបានចៅក្រមស៊ើបសួរសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញតាមដីកាសម្រេចលេខ៨០ “ល” ព្រ.ទ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ រួចហើយ។ ដូចនេះ តុលាការមិនពិចារណាទៀតឡើយ។

គ-ទូរស័ព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក IPHONE ពណ៌ស និងស្រោមអនាម័យប្រើរួចចំនួន ០២ និងស្រោមអនាម័យមិនទាន់ប្រើ មួយចំនួន គប្បីសម្រេចរឹបអូស។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៧ (ប្រាំពីរ) ឆ្នាំ។

ពីបទ **សញ្ញារកម្មមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅផ្ទះលេខ៣៣ ផ្លូវបេតុង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីអំឡុងដើមឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥ និងមាត្រា២៧ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

**២-វត្ថុតាងរួមមាន៖**

ក-ទូរស័ព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក IPHONE ពណ៌ស

ខ-ស្រោមអនាម័យប្រើរួចចំនួន ០២ និងស្រោមអនាម័យមិនទាន់ប្រើ មួយចំនួន

ត្រូវរឹបអូស។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឧត្តម ប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១៣រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner